ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ ថក ៣១ /២០២៥ កបទ.សអ

# សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១. នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០២៥ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានផ្តល់បទសម្ភាសន៍ដល់ទូរទស្សន៍ជាតិកម្ពុជា (ទទក) ស្តីពីលទ្ធផលនៃកិច្ចប្រជុំត្រីភាគីកម្ពុជា-ថៃ-ចិន ស្តីពីស្ថានភាពបច្ចុប្បន្នរវាងកម្ពុជា និងថៃ ដែលធ្វើឡើងនាថ្ងៃដដែល នៅខេត្តយូណាន ប្រទេសចិន។ ក្នុងបទសម្ភាសន៍ ការលើកឡើងរបស់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** អំពីការប្រើប្រាស់យន្តហោះគ្មានមនុស្សបើកក្នុងជម្លោះកម្ពុជា-ថៃនាពេលថ្មីៗនេះ ត្រូវបានយកមកផ្សព្វផ្សាយខុសពីបរិបទ ដែលបណ្តាលឱ្យមានការយល់ច្រឡំចំពោះសេចក្តីថ្លែងការណ៍របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងមានប្រព័ន្ធផ្សព្វផ្សាយជាច្រើនបានសុំការបំភ្លឺ។

២. ទាក់ទងនឹងការរក្សាបាននូវបទឈប់បាញ់ដ៏យូរអង្វែង **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការបង្កើតបណ្តាញទំនាក់ទំនងជាប្រចាំនៅកម្រិតរដ្ឋមន្ត្រីការបរទេស និងរវាងយោធាកម្ពុជា និងថៃ ដើម្បីទប់ស្កាត់ការកើនឡើងនៃភាពតានតឹង ដែលមិនចាំបាច់ដោយសារឧប្បត្តិហេតុតូចតាច ដូចជាការរាយការណ៍អំពីការដាក់ពង្រាយយន្តហោះគ្មានមនុស្សបើកឆ្លងព្រំដែន ដែលភាគីទាំងពីរអាចផ្ទៀងផ្ទាត់បានភ្លាមៗ ដើម្បីបញ្ចៀសការយល់ច្រឡំ។

៣. **ឯកឧត្តម ប្រាក់ សុខុន** មិនបានលើកឡើងពីឧប្បត្តិហេតុយន្តហោះគ្មានមនុស្សបើកជាក់លាក់ណាមួយ ឬចំនួនយន្តហោះគ្មានមនុស្សបើក ដូចដែលបានរាយការណ៍បំភាន់ពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយ និងបទអត្ថាធិប្បាយមួយចំនួននោះឡើយ៕

ថ្ងៃអង្គារ ១១កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh